**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

Sabrina

# កិច្ចព្រមព្រៀងបន្ថែម

ស្តីពី

ការកំណត់ប្រាក់ឈ្នួល សំរាប់កម្មករនិយោជិតផ្នែកតុកាត់ក្នុងកំឡុងពេលព្យួរការងារជាបណ្ដោះអាសន្ន

៣៣✺៤៤

យោង: -សេចក្តីណែនាំ លេខ ០៤៥/២០ ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០២០ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការព្យួរកិច្ចសន្យាការងារ និងការផ្អាកបង់ភាគទាន ប.ស.ស សម្រាប់ រោងចក្រ សហគ្រាស គ្រឹះស្ថាន ក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរ ដោយសារជំងឺកូវីដ-១៩

-អនុសញ្ញារួមរវាងក្រុមហ៊ុន និងតំណាងសហជីពស៊ីខៅខ្មូ មានភាពតំណាងបំផុត ប្រចាំក្រុមហ៊ុន ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩

ដោយឥទ្ធិពលនៃជំងឺកូវីដ-១៩ បានបន្តបង្កនូវផលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការផលិតកម្មរបស់ក្រុមហ៊ុន និងការធ្លាក់ចុះនូវការបញ្ជាទិញរបស់អ្នកបញ្ជាទិញ បានធ្វើអោយក្រុមហ៊ុន ពុំមានចំនួនបញ្ជាទិញគ្រប់គ្រាន់ និងពុំមានលទ្ធភាពក្នុងការផ្តល់ការងារជូនដល់បងប្អូនកម្មករនិយោជិត នៅក្នុងផ្នែកមួយចំនួន ។

ដើម្បីស្រោចស្រង់ស្ថានការណ៍ និងធ្វើយ៉ាងណាកុំឱ្យប៉ះពាល់ដល់ផ្នែក ឬក្រុមផ្សេងៗ ជាពិសេសប៉ះពាល់ដល់ក្រុមហ៊ុនទាំងមូល ហេតុដូច្នេះក្រុមហ៊ុន **សាប្រ៊ីណា** ខេមបូឌា និងសហជីពស៊ីខៅខ្មូ ដែលមានភាពតំណាងបំផុតប្រចាំក្រុមហ៊ុន បានប្រជុំពិភាក្សាជាមួយកម្មករនិយោជិត ក្នុងផ្នែកដែលទទួលរងការប៉ះពាល់ តាមរយៈតំណាងរបស់ពួកគាត់ និង បានឯកភាពគ្នាដូចខាងក្រោម៖

ប្រការ១ : ភាគីទាំងពីរ បានព្រមព្រៀងគ្នាថានឹងធ្វើការព្យួរការងារជាបណ្តោះអាសន្ន សម្រាប់កម្មករនិយោជិតក្នុង**ផ្នែកតុកាត់ និង ផ្នែកឃ្លាំងក្រណាត់** មួយចំនួន ។

ប្រការ២ : ការព្យួរការងារជាបណ្តោះអាសន្ននេះ នឹងធ្វើឡើងលើកម្មករនិយោជិត ចំនួន **១៦១នាក់** (មានស្ត្រី ចំនួន ១២៥នាក់) សម្រាប់រយៈពេលចំនួន **១៥ថ្ងៃ** ពោលពី **ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២២** រហូតដល់ **ថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ២០២២** ហើយធ្វើការបើកប្រាក់ឈ្នួល នៅ**ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២២** ទៅក្នុងគណនីធនាគាររបស់កម្មករនិយោជិតម្នាក់ៗ ។

ប្រការ៣ : ការព្យួរការងារជាបណ្តោះអាសន្ននេះ ភាគីក្រុមហ៊ុនបានឯកភាព ធ្វើការបង់ប្រាក់ឈ្នួលគោលចំនួន **៥០%** (ហាបសិបភាគរយ) និងបូកបន្ថែមនូវអត្ថប្រយោជន៍ការងារដទៃទៀត កំឡុងពេលដែលព្យួរការងារ ទៅក្នុងគណនីធនាគារ របស់កម្មករនិយោជិតម្នាក់ៗ ។

ប្រការ៤ : កិច្ចព្រមព្រៀងទាំងឡាយណាផ្ទុយពីខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ៥ : កិច្ចព្រមព្រៀងនេះមានប្រសិទ្ធិភាព និងអនុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃចន្ទ ៦រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅសាប្រ៊ីណា ថ្ងៃទី**១៤** ខែ**វិច្ឆិកា** ឆ្នាំ **២០២២**

សហជីព ប្រជាធិបតេយ្យកម្មករកាត់ដេរ
(សហជីព ស៊ីខៅខ្វ) ប្រចាំ ក្រុមហ៊ុន សាប្រ៊ីណា

| **ប្រធាន** | **អនុប្រធាន** | **លេខាធិការ** |
| --- | --- | --- |
| ឈា វិនុត | ឆន សុខយឿន | ពូន ផាន់ណា |

ក្រុមហ៊ុន សាប្រ៊ីណា

**នាយិកាក្រុមហ៊ុន**

សាប្រ៊ីណា(ខេមបូឌា) ហ្គាមិន ម៉ាញូហ្វាក់ធើរីង ខប
SABRINA (CAMBODIA) GARMENT MANUFACTURING CORP.

ឈិន ស៊ីងអ៊ីង